ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៤០/២១ - ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **រុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ២១ ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៦០៦ ២៣០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក គុំ គឹមសឿន | តំណាងក្រុមហ៊ុន |
| ២- លោក សាន ឡាយ | តំណាងក្រុមហ៊ុន |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ២១ ភូមិព្រែកបិ ឃុំកោះធំ(ខ) ស្រុកកោះធំ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៧ ២៣១ ០៩១ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក ជួង វាសនា | មន្ត្រីច្បាប់សហភាពការងារកម្ពុជា(CLC) |
| ២- លោក យ៉ាន សារ៉ាន់ | មន្ត្រីចងក្រង និងដោះស្រាយវិវាទសហភាពការងារកម្ពុជា(CLC) |
| ៣- លោក ធន សុងឃុយ | អ្នកសម្របសម្រួលសហភាពការងារកម្ពុជា(CLC) |
| ៤- កញ្ញា សេង ស្រីនិត | ជំនួយការសហភាពការងារកម្ពុជា(CLC) |
| ៥- លោក ស្រ៊ុន ឡេង | អនុប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិតប្រចាំក្រុមហ៊ុន |

៦- លោកស្រី អាត ស៊ីថុន ហិរញ្ញឹកសហជីពប្រជាធិបតេយ្យកម្មករនិយោជិតប្រចាំក្រុមហ៊ុន

៧- លោកស្រី សន រ៉េម សកម្មជនសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីតំណាងកម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបញ្ឈប់ការផ្តាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីពតទៅទៀត។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនជាប្រភេទរោងចក្រតម្បាញ។ ដូច្នេះ ជារៀងរាល់ឆ្នាំ ចាប់ពីខែសីហា ដល់ចុងឆ្នាំ ឬឈានដល់ដើមឆ្នាំបន្ទាប់ ក្រុមហ៊ុនពុំសូវមានការងារធ្វើឡើយ ហេតុនេះ ទើបក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារជូនកម្មករនិយោជិតដែលដល់កិច្ចសន្យាការងារតាមជាក់ស្តែង ពោលគឺពុំមានការរើសអើងឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ ៨៨១ ក.ប/អក/វក ចុះថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការស្នើសុំជួយដោះស្រាយលក្ខខណ្ឌការងារចំនួន ៦ចំណុច។ បន្ទាប់ពីបានទទួលបានបណ្តឹងនេះ អ្នកផ្សះផ្សាបានពិនិត្យសំណុំរឿងនេះតាមនីតិវិធីច្បាប់ ដោយពិនិត្យឃើញថា ក្នុងចំណោមចំណុចទាមទារទាំង ៦ចំណុច មាន ១ ចំណុច គឺជាវិវាទបុគ្គល (ចំណុចវិវាទទី៥) ហើយអ្នកផ្សះផ្សាបានដោះស្រាយផ្អែកតាមនីតិវិធីវិវាទបុគ្គល។

THE ARBITRATION COUNCIL

ដោយឡែក ចំណុចទាមទារទាំង ៥ចំណុច ដែលជាវិវាទការងាររួម អ្នកផ្សះផ្សាបានធ្វើការផ្សះផ្សា នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៤ចំណុច លើការទាមទារចំនួន ៥ចំណុច។ ចំណុចមិនសះជាដែលនៅសល់ចំនួន ១ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី លេខ ៨១១ ក.ប/អក/វក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសដើម្បីរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្ស៊ូម (zoom) ដោយបានចែកបន្ទប់រវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ ភាគីទាំងពីរមិនជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងភស្តុតាង និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ និងភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី៦ ខែមករា ឆ្នាំ ២០២២ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់នាយកក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ផ្ទេរសិទ្ធិជូន លោក គុំ គីមសឿន និងលោក សាន ឡាយ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ MOC-៥១២៧៦០៣៩ ពណ.ចបព ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥។

៣- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ ៥៣៧៨/២០១៦ អតប/អពជ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥។

៤- ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ២០២១ របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ PTS2021021004 អពជ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១។

៥- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ ០៦/២០១៦ ប.ស.ស.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ចុះបញ្ជិកា លេខ ១៧៩០/១៦ ក.ប.វ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជា-ជីវៈ ខេត្តកណ្តាល។

៧- លក្ខន្តិកៈក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី បានតម្កល់ទុកលេខ ៤៩៤៤/២០១៥ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៨- លិខិតចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ស្តីពីការមិនបន្តកិច្ចសន្យាការងារកម្មករនិយោជិតដែលដល់កាលកំណត់នៃកិច្ចសន្យាត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។

៩- លិខិតជូនដំណឹងមិនបន្តកិច្ចសន្យាការងារ របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី។

១០- លិខិតរបស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំទាស់លើឯកសារភស្តុតាង របស់ភាគីកម្មករនិយោជិតដែលដាក់បន្ថែមរបស់ភាគីកម្មករ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១។

១១- លិខិតលាលែង កាតសំគាល់ខ្លួន របស់ឈ្មោះ ស្រ៊ុន ឡេង, ហាំង សុខហុង, ស្រៀង លាប, អ៊ុយ សារិត, លឹម សារ៉ុន។

១២- ពាក្យសុំបំរើការងារ, អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ,សំបុត្របញ្ជាក់កំណើត, តារាងធ្វើតេស្ត សាកល្បងកម្មករចូលធ្វើការ, កិច្ចសន្យាការងារ របស់ឈ្មោះ ស្រ៊ុន ឡេង។

១៣- ពាក្យសុំបំរើការងារ, អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ,សំបុត្របញ្ជាក់កំណើត, តារាងធ្វើតេស្ត សាកល្បងកម្មករចូលធ្វើការ, កិច្ចសន្យាការងារ របស់ឈ្មោះ ហាំង សុខហុង។

១៤- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងកម្មករនិយោជិត និងសមាជិកសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី សូមគោរព

THE ARBITRATION COUNCIL

ជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីដាក់ជូនសារណាក្នុងសំណុំរឿងលេខ ០៩០/២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- កំណត់ហេតុរបស់ឈ្មោះ ស្រ៊ុន ឡេង ចុះថ្ងៃទី១៥, ៨, ២២, ២ ខែវិច្ឆិកា ឆ្នាំ២០២១។

៣- កំណត់ហេតុរបស់ឈ្មោះ ស្រៀង លាក ចុះថ្ងៃទី៣, ៤, ២១ ខែមិថុនា ឆ្នាំ២០២១។

៤- កំណត់ហេតុរបស់ឈ្មោះ ស្រៀង លាក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

៥- កំណត់ហេតុរបស់ឈ្មោះ ស្រៀង លាក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១។

៦- លិខិតជូនដំណឹងមិនបន្តកិច្ចសន្យា របស់ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី។

៧- លិខិតលាលែងរបស់ឈ្មោះ ហាំង សុខហុង។

៨- សៀវភៅការងាររបស់ឈ្មោះ អាន ស៊ីថុន។

៩- កាតសំគាល់ខ្លួនរបស់ឈ្មោះ ផាន ម៉េងភារី, ស្រៀង លាក, ហាំង សុខហុង, ម៉ាំង ឡុន។

១០- លិខិតរបស់ឈ្មោះ ស្រៀង លាប ជាប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីជូនដំណឹងពីលទ្ធផលអំពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្ម-ករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១។

១១- លិខិតរបស់ឈ្មោះ ស្រៀង លាប ជាប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី គោរពជូន លោកនាយកក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ស្តីពីជូនដំណឹងពីលទ្ធផលអំពីការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ ប្រធានសហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១។

១២- បញ្ជីឆាប់រហ័ស(EMS)។

១៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ ២០៦/២១ ក.ប/វ.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។

១៤- លិខិតលេខ ១១៣/២១ ក.ប/វ.ក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

THE ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេក-ស្តាយ ខូ អិលធីឌី លេខ ៨៤១ ក.ប/អក/វក ចុះថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិលធីឌី លេខ ០១០/២១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៤៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៤៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី មានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ និងតម្បាញ និងមានជួលកម្មករនិយោជិតសរុបចំនួន ៥០០នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី លេខ ៨១១ ក.ប/អក/វក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១)*
- សហជីពប្រជាធិបតេយ្យកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ូ(ខេមបូឌា) ខេសមើរ ថេកស្តាយ ខូ អិល-ធីឌី ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខ ២០៦/២១ ក.ប/វ.ប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ និងមានលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព លេខ ១១៣/២១ កប/វ.ក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ដែលមានថ្នាក់ដឹកនាំសហជីពចំនួន ៣នាក់ មានឈ្មោះ ១. លោក ស្រៀង លាប ជាប្រធាន, ២. លោក ស្រ៊ុន ឡេង ជាអនុប្រធាន និង៣. លោក ហាំង សុខហុង ជាលេខាធិការ។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០១០/២១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានកម្មករនិយោជិតចំនួន ៣នាក់ រួមមាន ៖ ១. លោក ស្រ៊ុន ឡេង, ២. លោក ហាំង សុខហុង, ៣. លោកស្រី អាត ស៊ីថុន។
- យោងតាមពាក្យបណ្តឹង និងលិខិតប្រគល់សិទ្ធរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតចំនួន ៨នាក់ បានផ្តិតស្នាមមេដៃផ្ទេរសិទ្ធិនៅ

ក្នុងការទាមទារ មានដូចជា ៖ ១. ស្រ៊ុន ឡេង, ២. សន រ៉េម, ៣.អាត ស៊ីថុន, ៤. ផាន ម៉េងភារី, ៥. ហាំង សុខហុង, ៦. មាំង ឡូន, ៧. អុក ណារិន, និង៨. សន សារ៉ាយ។

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបញ្ឈប់ការផ្ដាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីពតទៅទៀត**

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ប្រសិនបើកម្មករនិយោជិតជាស្ថាបនិកសហជីព បានប្រព្រឹត្តកំហុសធ្ងន់ ឬប្រព្រឹត្តខុស និយោជកអាចបញ្ឈប់ពួកគាត់ពីការងារបាន។
- ភាគីនិយោជកបញ្ជាក់ថាមិនអាចផ្ដល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុដូចខាងក្រោម ៖
  - និយោជកបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ដោយផ្អែកលើការអនុវត្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា គឺនិយោជកមិនមានការរើសអើងស្ថាបនិក ឬសកម្មជនសហជីពនោះទេ។
  - បច្ចុប្បន្ននេះ និយោជកបានជូនដំណឹងបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួនប្រហែល ២០០នាក់។
  - ភាគីកម្មករនិយោជិតបានយល់ច្បាស់អំពីស្ថានភាពការងារនៅក្នុងក្រុមហ៊ុន គឺនិយោជកមានការងារឱ្យកម្មករនិយោជិតធ្វើចាប់ពីខែកុម្ភៈ រហូតដល់ខែកញ្ញា នៃឆ្នាំនីមួយៗប៉ុណ្ណោះ។ ចាប់ពីខែតុលា រហូតដល់ចុងឆ្នាំនីមួយៗ និយោជកមិនមានការបញ្ជាទិញ និងមិនមានការងារឱ្យកម្មករនិយោជិតធ្វើនោះទេ។ ហេតុនេះ និយោជកបានបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា របស់កម្មករនិយោជិតដែលមានដល់កាលកំណត់។
  - រៀងរាល់ចុងឆ្នាំនីមួយៗ និយោជកតែងតែមានការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៦០ភាគរយ រហូតដល់ ៧០ភាគរយ និងនៅដើមឆ្នាំនីមួយៗ និយោជកប្រកាសឱ្យកម្មករនិយោជិតមកធ្វើការវិញ នៅពេលមានការងារធ្វើ។
- ភាគីកម្មករនិយោជិតបានដាក់សារណានៃសំណុំរឿងលេខ ០៤០/២១-ក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ៖ *"...១) ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការផ្ដាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីព*
  *ក)អង្គហេតុនៃការទាមទារ*

  ...

  *បន្ទាប់ពីនិយោជកបានរោងចក្របានទទួលដំណឹងអំពីការបង្កើតសហជីពរួមមក ថ្នាក់ដឹកនាំ សកម្មជន និងកម្មជនសហជីព ត្រូវបានក្លាយជាគោលដៅរងការធ្វើទុក្ខបុកម្នេញ...ព្រមទាំងចុងក្រោយត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ...*

  *...រហូតមកដល់ពេលនេះ ថ្នាក់ដឹកនាំ សកម្មជន និងស្ថានិកសហជីពចំនួន ៩នាក់ ត្រូវបានរោងចក្រ....ផ្ដាច់កិច្ចសន្យាការងារ...គឺជារូបភាពរើសអើងសហជីពក្នុងរោងចក្រ...*

  *គ) ភស្តុតាង*

  - ...
  - *កំណត់ហេតុ ស្ដីពីការធ្វើទុក្ខបុកម្នេញ របស់ក្រុមហ៊ុន មកលើថ្នាក់ដឹកនាំ និងស្ថានិកសហជីព*

- ...។"

- ភាគីនិយោជកបានដាក់ឯកសារជំទាស់ឯកសារកេស្តុតាងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ៖ *"...ជំទាស់: កំណត់ហេតុភាគីកម្មករ និងការអេះអាង*
*...ចំពោះកំណត់ហេតុដែលលើកឡើងដោយឈ្មោះ ស្រ៊ិន ឡេង ហាំង សុខហុង គឺជាកំណត់ហេតុដែលធ្វើឡើងគ្រាន់តែជាការឈប់ឃើញផ្ទាល់ខ្លួន និងជាការលើកឡើងផ្ទុយពីការពិត គ្មានមូលដ្ឋានច្បាស់លាស់...ក្រុមហ៊ុនមិនដែលបានគំរាមគំហែងទៅលើកម្មករណាមួយឡើយ។...*
*...ចំពោះកម្មករនិយោជិតឈ្មោះ ស្រៀង លាប គឺបានលាឈប់ពីការងារ....*
*...ការមិនបន្តកិច្ចសន្យាការងារកម្មករនេះក្រុមហ៊ុនមិនមានការរើសអើងចំពោះសហជីព ស្ថាបនិកសហជីព ឬចំពោះកម្មករណាម្នាក់ឡើយ គឺក្រុមហ៊ុនអនុវត្តកិច្ចសន្យាមានថេរវេលាកំណត់តាមច្បាប់ស្តីពីការងារតែប៉ុណ្ណោះ។..."*។

**ចំណុចវិវាទបន្ថែម ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពចំនួន ៩នាក់ ចូលធ្វើការវិញ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល**

- ភាគីកម្មករនិយោជិតលើកឡើងថា ៖
  - ០ កម្មករនិយោជិតដែលជាថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពប្រជាធិបតេយ្យកម្មករនិយោជិតមានចំនួន ៩នាក់ រួមមាន ៖
    - សន រ៉េម ចូលធ្វើការថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៨ ត្រូវបាននិយោជកជូនដំណឹងបញ្ចប់កិច្ចសន្យាការងារនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ (ជាស្ថាបនិកសហជីព)។
    - មាំង ឡុន ចូលធ្វើការនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវនិយោជកបញ្ឈប់ពីការងារនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ (ជាស្ថាបនិកសហជីព)។
    - អុក ណារិន បានចូលធ្វើការចំនួន ៤ឆ្នាំហើយ រហូតដល់បច្ចុប្បន្ន ត្រូវនិយោជកបញ្ឈប់ពីការងារថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ (ជាស្ថាបនិកសហជីព)។
    - អាត ស៊ីថុន ចូលធ្វើការនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ បច្ចុប្បន្ននេះ ត្រូវនិយោជកជូនដំណឹងបញ្ចប់កិច្ចសន្យាការងារនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ (ជាស្ថាបនិកសហជីព)។
    - ចំណែកកម្មករនិយោជិតឈ្មោះ ផាន ម៉េងភារី (ជាស្ថាបនិកសហជីព), លឹម វ៉ុន, និង អ៊ុយ សារិត មិនមានព័ត៌មានអំពីកាលបរិច្ឆេទចូលធ្វើការ និងកាលបរិច្ឆេទបញ្ឈប់ពីការងារនោះទេ។
    - ករណីកម្មករនិយោជិតចំនួន ២នាក់ ផ្សេងទៀត ភាគីកម្មករនិយោជិតមិនបានបញ្ជាក់ឈ្មោះជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។
  - ០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្សះផ្សាសំណុំរឿងនេះនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ ២០២១ ដោយនិយោជកបញ្ឈប់កម្មករនិយោជិតពីការងារ នៅក្រោយពេលផ្សះផ្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

THE ARBITRATION COUNCIL

- ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពប្រជាធិបតេយ្យកម្មករនិយោជិតធ្វើឡើងនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ និងទទួលបានបញ្ជិកាសហជីព នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - និយោជកបានបញ្ឈប់កម្មករនិយោជិតដែលជាថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពខាងលើ នៅក្រោយពេលផ្សះផ្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយពួកគាត់ក៏មានឈ្មោះនៅក្នុងបណ្តឹងដើមផងដែរ។
  - កម្មករនិយោជិតមិនចង់យកចំណុចវិវាទបន្ថែមនេះទៅផ្សះផ្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ ព្រោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងដោះស្រាយចំណុចនេះតាមនីតិវិធីរបស់វិវាទបុគ្គល និងមិនបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធ្វើការដោះស្រាយនោះទេ។
  - និយោជកបញ្ឈប់កម្មករនិយោជិតជាថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពខាងលើពីការងារក្នុងរូបភាពនៃការរើសអើងសហជីព។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគួរតែមានឆន្ទានុសិទ្ធិក្នុងការសម្រេចសេចក្តីជូនកម្មករនិយោជិតចំពោះការបញ្ឈប់ពីការងារនេះ ពីព្រោះភាគីកម្មករនិយោជិតមានទំនុកចិត្តលើការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

- ភាគីនិយោជកបញ្ជាក់មូលហេតុដែលមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានដូចខាងក្រោម ៖
  - យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានចំណុចមិនសះជាតែមួយចំណុចប៉ុណ្ណោះ ហេតុនេះ ភាគីកម្មករនិយោជិតមិនអាចយកចំណុចវិវាទដែលមិនមានក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនេះ ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាបានទេ។
  - ការអនុវត្តនៅក្នុងក្រុមហ៊ុន គឺនិយោជកប្រើប្រាស់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាជាមួយកម្មករនិយោជិត ដូចនេះ នៅពេលកិច្ចសន្យាការងារដល់កាលកំណត់ នោះនិយោជកនឹងជូនដំណឹងមិនបន្តកិច្ចសន្យាការងារ គឺមិនពាក់ព័ន្ធនឹងការរើសអើងចំពោះស្ថាបនិក ឬសកម្មជនសហជីពនោះទេ។
  - និយោជកសម្រេចមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិត គឺអនុវត្តស្របតាមបទបញ្ជាផ្ទៃក្នុង និងកិច្ចសន្យាការងាររបស់កម្មករនិយោជិត។
  - បច្ចុប្បន្ននេះ និយោជកក៏បានសម្រេចបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិតដទៃទៀតដែលដល់ពេលកំណត់ចំនួនប្រហែល ២០០នាក់ ដោយមូលហេតុថា និយោជកមិនមានការងារឱ្យកម្មករនិយោជិត និងមិនមានការបញ្ជាទិញ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបញ្ឈប់ការផ្តាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីព**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបញ្ឈប់ការផ្តាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីពដែរ ឬទេ?

យោងតាមសាណារបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បានបញ្ជាក់ថា និយោជកបានផ្តាច់កិច្ចសន្យាការងារថ្នាក់ដឹកនាំ សកម្មជន និងស្ថានិកសហជីព គឺក្នុងរូបភាពរើសអើងសហជីព។

មាត្រា ៦២ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា ៖ *"...និយោជកមិនត្រូវរើសអើងដោយយកលេសអំពីការជាប់ទាក់ទងនឹងការកាន់តំណែងជាថ្នាក់ដឹកនាំរបស់សហជីព ឬការចូលរួមរបស់កម្មករនិយោជិត ក្នុងសកម្មភាពសហជីពដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការ ការដឹកនាំការបែងចែកការងារ ការដំឡើងតួនាទី មុខតំណែង ការផ្តល់ប្រាក់ឈ្នួល ការផ្តល់អត្ថប្រយោជន៍ វិធានការដាក់ពិន័យ និងការបញ្ចប់កិច្ចសន្យាការងារដែលរួមបញ្ចូលទាំងការបញ្ឈប់ ឬការមិនបន្តកិច្ចសន្យាការងារដែលមានជាបន្តបន្ទាប់ដោយខុសនីតិវិធី។"*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាង ក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤៨/០៧-ប៉ាយ ហ៊ី និងលេខ ៣៤/១១-លីម ឡាញ ហេតុផលនៃចំណុចវិវាទទី៧)*

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ពន្ធ័ទៅនឹងសំណុំរឿង ដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើងដែរ ឬទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣/០៣-តុង ហ្គា ហេតុផលនៃចំណុចវិវាទទី១០, លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃចំណុចវិវាទទី៤, លេខ ១៩/០៤-ក្បាលកោះ ហេតុផលនៃចំណុចវិវាទទី១, លេខ ១៧/០៧-ធាម ចិចថាយ ហេតុផលនៃចំណុចវិវាទទី១, លេខ ៥៦/០៩-សាន់តិច ហេតុផលនៃចំណុចវិវាទទី១ និងលេខ ២៨៣/១៤-លៀន ហ្វា (ខេមបូឌា) ហ្គាមិនខូ.,អិលធីឌី ហេតុផលនៃចំណុច វិវាទទី១០)*

លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលច្រានចោលការអះអាងរបស់ភាគីវិវាទ ប្រសិនបើភាគីដែលធ្វើការអះអាងមិនមានភស្តុតាងជាក់លាក់ ដើម្បីសម្អាងលើការទាមទារនោះទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦៣/០៤-សាញ វ៉ែល ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៩/០៦-សៅជ័បាយ ហេតុផលនៃចំណុចវិវាទទី៥, លេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃចំណុចវិវាទទី៤, លេខ ៥១/០៧-ហ្គោល ហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ១៥៤/១៣-បូវយើរ ហ្គាមេន ហ្វេកធើរី ហេតុផលនៃចំណុចវិវាទទី២)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ប្រការ ២៥ នៃប្រកាស ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវមានសេរីភាពក្នុង*

THE ARBITRATION COUNCIL

*ការកំណត់អំពីភាពដែលអាចទទួលយកបាន ភាពពាក់ព័ន្ធភាពសំខាន់ និងទំងន់នៃភស្តុតាង និងមានសេរីភាពក្នុងការកំណត់ឱ្យភាគីណាមួយ លើកភស្តុតាងមកបញ្ជាក់ទៀតផង។"*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រៅពីការអះអាងនៅក្នុងសារណា ភាគីកម្មករនិយោជិត បានដាក់កំណត់ហេតុរបស់កម្មករនិយោជិតចំនួន ១១ច្បាប់ ផ្សេងៗគ្នា ដោយក្នុងនោះមានកំណត់ហេតុរបស់កម្មករនិយោជិតឈ្មោះ ស្រ៊ុន ឡេង ចំនួន ៥ច្បាប់ ដែលមានចុះកាលបរិច្ឆេទស្ទួនគ្នាចំនួន ១ច្បាប់ និងកំណត់ហេតុរបស់កម្មករនិយោជិតឈ្មោះ ស្រៀង លាប ចំនួន ៦ច្បាប់ ដែលមានចុះកាលបរិច្ឆេទស្ទួនគ្នាចំនួន ១ច្បាប់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កំណត់ហេតុទាំងនោះ គឺរៀបរាប់ពីការចូលរួមប្រជុំជាមួយនិយោជក ទាក់ទងអំពីការជូនដំណឹងបញ្ចប់កិច្ចសន្យា និងការសន្ទនាគ្នាផ្សេងៗ។ បន្ទាប់ពីបានពិនិត្យលើកំណត់ហេតុរបស់ភាគីកម្មករនិយោជិត និងផ្អែកតាមប្រការ ២៥ នៃប្រកាស ០៩៩ សកបយ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កំណត់ហេតុរបស់ភាគីកម្មករនិយោជិត គឺមិនមានបន្ទុកគ្រប់គ្រាន់ដែលអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿជាក់ថា និយោជកពិតជាបានធ្វើទុក្ខបុកម្នេញលើស្ថាបនិកសហជីពនោះទេ។ លើសពីនេះ និយោជកក៏បានជំទាស់ដែរថា កំណត់ហេតុរបស់កម្មករនិយោជិតធ្វើឡើងគ្រាន់តែជាការយល់ឃើញផ្ទាល់ខ្លួន និងជាការលើកឡើងផ្ទុយពីការពិត គ្មានមូលដ្ឋានច្បាស់លាស់ ហើយក្រុមហ៊ុនមិនដែលបានគំរាមគំហែងទៅលើកម្មករនិយោជិតណាមួយឡើយ។

ក្រៅពីកំណត់ហេតុរបស់កម្មករនិយោជិតចំនួន ១១ច្បាប់ ខាងលើនេះ ភាគីកម្មករនិយោជិតមិនបានផ្តល់ភស្តុតាងណាមួយ ដើម្បីគាំទ្រអំណះអំណាងដែលថា និយោជកបានផ្តាច់កិច្ចសន្យាការងារថ្នាក់ដឹកនាំសកម្មជន និងស្ថានិកសហជីពមានពាក់ព័ន្ធ និងការរើសអើងសហជីព ដើម្បីក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណានោះទេ។ ម្យ៉ាងវិញទៀត ភាគីនិយោជកបានលើកឡើងថា និយោជកបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ដោយផ្អែកលើការអនុវត្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា គឺនិយោជកមិនមានការរើសអើងស្ថាបនិក ឬសកម្មជនសហជីពនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិត គឺមិនពាក់ព័ន្ធ និងការរើសអើងសហជីពនោះទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបញ្ឈប់ការផ្តាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីព។

**ចំណុចវិវាទបន្ថែម ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពចំនួន ៩នាក់ ចូលធ្វើការវិញ ព្រមទាំងសងរំលឹកប្រាក់ឈ្នួល***

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា មិនមានចំណុចវិវាទនេះ នៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្តាយ ខូអិលធីឌី ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទបន្ថែមនេះ ដោយមូលហេតុថា និយោជកបានបញ្ឈប់ការងារកម្មករនិយោជិតដែលជាថ្នាក់ដឹកនាំ ស្ថាបនិក និងសកម្មជនសហជីពនៅក្រោយពេលផ្សះផ្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការក្នុងការដោះស្រាយចំណុចវិវាទបន្ថែមនេះដែរ ឬទេ?

THE ARBITRATION COUNCIL

កថាខណ្ឌទី១ មាត្រា ៣១២ នៃច្បាប់ស្តីពីការងារចែងថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។"*

ប្រការ ៣៣ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ។"*

យោងតាមមាត្រា ៣១២ នៃច្បាប់ស្តីពីការងារ និងប្រការ ៣៣ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែចំណុចវិវាទ ដែលមាននៅក្នុងរបាយការណ៍មិនសះជាប៉ុណ្ណោះ។ ចំណែកឯចំណុចវិវាទដែលមិនមាននៅក្នុងរបាយការណ៍មិនសះជា ដែលភាគីលើកឡើងនៅក្នុងសវនាការបញ្ជាក់ពីការទាមទារបន្ថែម ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការពិចារណាបាន លុះត្រាតែចំណុចវិវាទនោះ គឺជាបញ្ហាកើតក្រោយការធ្វើកំណត់ហេតុ ដែលជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤២/០៧-សោធន៍ បេ ហេតុផលនៃចំណុចវិវាទទី៣, លេខ ០៦/០៨-យីង ឡែន ហេតុផលនៃចំណុចវិវាទទី២, លេខ ៣៤/០៩-សាន់តិច, លេខ ០១២/១៦-ស្រាបៀរកម្ពុជា ខេមប្រ៊ូវ ហេតុផលនៃចំណុចវិវាទបន្ថែម, លេខ ២២២/១៦-ហ្វូហ្វ ហេតុផលនៃចំណុចវិវាទបន្ថែម, លេខ ០៦៧/១៩-វ៉ៃនជើរេន អ៊ីកែលី (ខេមបូឌា) ខូអិលធីឌី ហេតុផលនៃចំណុចវិវាទបន្ថែម, និងលេខ ០១៧/២១-ហ្វីនិក ស៊ីយូរ៉េធី ស៊ីស្ទឹម ហេតុផលនៃចំណុចវិវាទបន្ថែម)*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថាតើ (១) វិវាទនេះ ជាបញ្ហាកើតក្រោយការធ្វើកំណត់ហេតុ និង(២) ជាផលវិបាកផ្ទាល់នៃការវិវាទដែលបានប្តឹងនោះដែរ ឬទេ?

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សះផ្សាសំណុំរឿងនេះ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១។ ចំពោះកម្មករនិយោជិតចំនួន ៣នាក់ ឈ្មោះ ១. សន រ៉េម, ២. មាំង ឡូន, និង ៣. អុក ណារិន ត្រូវបាននិយោជកបញ្ចប់កិច្ចសន្យាការងារ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលការបញ្ចប់កិច្ចសន្យាការងារនេះ គឺកើតឡើងមុនថ្ងៃផ្សះផ្សានៅក្រសួងទការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទទាក់ទងនឹងកម្មករនិយោជិតចំនួន ៣នាក់ ខាងលើ មិនមែនជាវិវាទកើតក្រោយការធ្វើកំណត់ហេតុមិនសះជា ដែលជាផលវិបាកផ្ទាល់នៅក្នុងសំណុំរឿងនេះនោះទេ។

ម្យ៉ាងវិញទៀត ចំពោះកម្មករនិយោជិតឈ្មោះ អាត ស៊ីថុន ត្រូវបញ្ចប់កិច្ចសន្យាការងារ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២។ ដោយឡែក សវនាការអាជ្ញាកណ្តាលនៃសំណុំរឿងនេះ បានធ្វើឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ហេតុនេះ គឺមិនមែនជាផលវិបាកនៅសំណុំរឿងនេះនោះទេ ពីព្រោះចាប់ពីថ្ងៃផ្សះផ្សា រហូតមកដល់ថ្ងៃសវនាការ ភាគីនិយោជកមិនទាន់បានបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតឈ្មោះ អាត ស៊ីថុន នៅឡើយទេ។ ចំពោះកម្មករនិយោជិតចំនួន ៣នាក់ ផ្សេងទៀត មានឈ្មោះ ១. ផាន ម៉េងភារី, ២. លឹម រ៉ុន, និង ៣. អ៊ុយ សារិត មិនមានព័ត៌មានអំពីកាលបរិច្ឆេទចូលធ្វើការ និងកាលបរិច្ឆេទបញ្ឈប់ពីការងារនោះទេ ហើយចំណែក

កម្មករនិយោជិតចំនួន ២នាក់ទៀត ភាគីកម្មករនិយោជិតក៏មិនបានបញ្ជាក់ឈ្មោះជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចពិចារណាជូនកម្មករនិយោជិតចំនួន ៥នាក់ ខាងលើដែលមិនមានព័ត៌មានច្បាស់លាស់នោះទេ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា វិវាទទាក់ទងកម្មករនិយោជិតទាំង ៩នាក់ ខាងលើដែលមិនមាននៅក្នុងរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជុន ស៊ូ (ខេមបូឌា) ខេសមើរ ថេកស្ដាយ ខូអិលធីឌី ដែលក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺមិនមែនជាផលវិបាកផ្ទាល់នៃចំណុចវិវាទទី១ ទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនពិចារណាលើការទាមទារចំណុចវិវាទបន្ថែមរបស់កម្មករនិយោជិតនេះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធពិចារណាការទាមទារចំណុចវិវាទបន្ថែម។

យោងតាមការបង្ហាញភស្ដុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបញ្ឈប់ការផ្ដាច់កិច្ចសន្យាការងាររបស់ស្ថាបនិកសហជីព។

**ចំណុចវិវាទបន្ថែម ៖**

- បដិសេធពិចារណាការទាមទារចំណុចវិវាទបន្ថែម។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណន**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **នួន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL